ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការបើកផ្តល់ប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗ
# ជូនបងប្អូនកម្មករនិយោជិតនៃរោងចក្រ ញូ ស្កាយ ព្រីនធីង (NEW SKY PRINTING)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតនៃ **រោងចក្រ ញូ ស្កាយ ព្រីនធីង (NEW SKY PRINTING)** មានអាសយដ្ឋាន នៅផ្ទះលេខ B1 ផ្លូវ២១៧ ភូមិបាគូ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលជាសាខានៃក្រុមហ៊ុន វ៉ាយ & ដាប់បែលយូ ហ្គាមេន (Y & W GARMENT CO., LTD.) ជ្រាបថា ក្រសួងនឹងចាប់ផ្តើមបើកផ្តល់ប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗ ជូនបងប្អូនកម្មករនិយោជិត នៅសាលាខណ្ឌដង្កោ មានអាសយដ្ឋាន ផ្លូវ២១៧ ភូមិថ្មី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ចាប់ពីវេលាម៉ោង ៣រសៀល ថ្ងៃអង្គារ ទី២៦ ខែមីនា ឆ្នាំ២០២៤ នេះតទៅ តាមបញ្ជីឈ្មោះ និងលេខរៀង ដែលក្រសួងបិទផ្សាយនៅសាលាខណ្ឌដង្កោ។

សូមបងប្អូនកម្មករនិយោជិតយកមកជាមួយនូវឯកសារ ដូចខាងក្រោម៖

១. ប័ណ្ណ (កាត) សម្គាល់ខ្លួនកម្មករនិយោជិត (ច្បាប់ដើម) ឬកិច្ចសន្យាការងារ និងសៀវភៅការងារកម្មករនិយោជិត ឬប័ណ្ណសមាជិក ប.ស.ស. ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន

២. ប័ណ្ណបើកប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតម្នាក់ៗ (បើមាន)។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក៖

- លោក ខុច សុទ្ធមុត ០១២ ៨០៧ ៩០៧
- លោក មុំ បុណា ០៩២ ៥០០ ៦៣៤

ក្រសួងបាននិងកំពុងបន្តស្រាវជ្រាវរករោងចក្រផ្សេងៗ ដែលជាសាខានៃក្រុមហ៊ុន វ៉ាយ & ដាប់បែលយូ ហ្គាមេន ដើម្បីមានវិធានការធានាផលប្រយោជន៍ជូនបងប្អូនកម្មករនិយោជិតផ្សេងទៀត។ សូមបងប្អូនកម្មករនិយោជិត ចូលរួមសហការផ្តល់ព័ត៌មានមកកាន់ក្រសួងឱ្យបានឆាប់រហ័សតាមរយៈប្រព័ន្ធ Hotline លេខ "១២៩៧" ឬ "១២៨៦"។

ទន្ទឹមនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមអំពាវនាវដល់បងប្អូនកម្មករនិយោជិតដែលមិនទាន់មានការងារថ្មីធ្វើ សូមមកទទួលឱកាសការងារថ្មីពីមជ្ឈមណ្ឌលការងារចល័តនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដែលប្រចាំការនៅខាងមុខសាលាខណ្ឌដង្កោ ឬទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០៧៧ ២៣២ ៣៧៨/ ០១៦ ៧៨៦ ៦៥៥។

អាស្រ័យហេតុនេះ សូមបងប្អូនកម្មករនិយោជិតទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ២រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៤